**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ**.......................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ ក្រសួងការពារជាតិសឹង្ហបូរី **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ អញ្ជើញចូលរួមកិច្ចប្រជុំកំពូលសន្តិសុខអាស៊ីលើកទី១៨(The 18th IISS Shangri-La Dialogue) ដែលនឹងប្រព្រឹត្តទៅ ពីថ្ងៃទី៣១ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩ នៅប្រទេសសឹង្ហបូរី។

ក្នុងអំឡុងពេលបំពេញទសនកិច្ចការងាររយៈពេល៣ថ្ងៃក្នុងប្រទេសសឹង្ហបូរី គណៈប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិដឹកនាំដោយ **សម្តេចពិជ័យសេនា ទៀ បាញ់** គ្រោងនឹងអញ្ជើញចូលរួមផងដែរក្នុងកិច្ចប្រជុំទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសពាក់ព័ន្ធក្នុងតំបន់។

ដូចជាឆ្នាំមុនៗដែរ កិច្ចប្រជុំកំពូលសន្តិសុខអាស៊ីលើកទី១៨(The 18th IISS Shangri-La Dialogue) ឆ្នាំ២០១៩ ក្នុងប្រទេសសឹង្ហបូរី លើកនេះនឹងផ្តល់ឱកាសយ៉ាងច្រើនសម្រាប់កិច្ចប្រជុំទ្វេភាគី និងពហុភាគីដល់តំណាង និងប្រមុខការពារជាតិទាំងអស់ពីគ្រប់ប្រទេស ដើម្បីប្រជុំពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាស្តីពីបញ្ហាសន្តិសុខក្នុងតំបន់ ៕

*ថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣*

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh